BAYON ERA HOTEL
巴戎时代酒店
*Reliving the Exotic Past of Bayon*
★★★★★

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
## រវាងនិយោជក និង
## និយោជិតក្នុងការព្យួរអាជីវកម្មបណ្តោះអាសន្នរបស់សណ្ឋាគារបាយ័នអេរ៉ា ហូថែល ឧបភើរេសិន

នាងខ្ញុំ គី មុយឡេង ភេទ ស្រី សញ្ជាតិ ខ្មែរ ជាម្ចាស់ សណ្ឋាគារបាយ័នអេរ៉ា ហូថែល ឧបភើរេសិន ដែលមានទីតាំងស្ថិតនៅភូមិ ខ្នារ សង្កាត់ ជ្រាវ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលតំណាងឲ្យ ភាគី "ក"។

និយោជិតទាំងអស់ដែលបំរើការងារនៅក្នុង សណ្ឋាគារបាយ័នអេរ៉ា ហូថែល ឧបភើរេសិន ដែលមានទីតាំងស្ថិតនៅភូមិ ខ្នារ សង្កាត់ ជ្រាវ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលតំណាងឲ្យ ភាគី "ខ"។

សណ្ឋាគារបាយ័ន អេរ៉ា ហូថែល ឧបភើរេសិន នឹងត្រូវផ្អាកដំណើរការអាជីវកម្មជាបណ្តោះអាសន្ន ចាប់ពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២១ ដោយសារយើងខ្ញុំ កំពុងជួបប្រទះគ្មានភ្ញៀវស្នាក់នៅដែលបណ្តាលមកពីវិបត្តិសកលនៃមេរោគ កូវីត១៩ ជាហេតុធ្វើអោយសណ្ឋាគារ គ្មានប្រាក់ចំណូលដើម្បីប្រតិបត្តការអាជីវកម្មទៀតបាន។

ដូចច្នេះទើបក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ បុគ្គលិកចំនួន ១២៥នាក់ ចំពោះការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុន (និយោជក) មិនបានផ្តល់ប្រាក់ឧបត្ថមជូនកម្មករនិយោជិតទេ

ដោយក្រុមហ៊ុនបានពិភាក្សាជាមួយថ្នាក់ដឹកនាំនិងប្រតិភូបុគ្គលិករួមទាំងប្រធានក្រុមរហូតដល់មានការព្រមព្រៀង ដូចខាងក្រោម៖

ប្រការមួយ៖ និយោជក(ភាគី"ក" ) រក្សាកិច្ចសន្យាការងាររបស់បុគ្គលិកនៅដដែល និងអត្ថប្រយោជន៍ផ្សេងៗ ដូចដែលមានចែងក្នុងកិច្ចសន្យាការងាររបស់សណ្ឋាគារ បាយ័នអេរ៉ា ហូថែល ឧបភើរេសិន

ប្រការពីរ៖ និយោជិត (ភាគី "ខ" ) បានព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាកាងាររបស់ សណ្ឋាគារបាយ័នអេរ៉ា ហូថែល ឧបភើរេសិន ដូចដែលបានរៀបរាប់ខាងលើ

ដើម្បីឲ្យប្រាកដ យើងខ្ញុំទាំងពីរភាគី សូមធ្វើការផ្ដិតស្នាមមេដៃស្ដាំទុកជាភស្តុតាង។

សៀមរាប ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២១

ភាគី "ក"

គី មុយឡេង

ឈ្មោះ និងស្នាមមេដៃស្ដាំភាគី "ខ"

| | | |
|---|---|---|
| ឈ្មោះ ឃឹម សុផល<br>តួនាទី មេក្រុម សន្តិសុខ | ឈ្មោះ សុខ ឆៃ<br>តួនាទី បើកឡាន | ឈ្មោះ សុខ ជា<br>តួនាទី សន្តិសុខ |
| ឈ្មោះ ប៊ុន ឃឿន<br>តួនាទី ប្រធាន សន្តិសុខ | ឈ្មោះ អឹត វីរៈ<br>តួនាទី សន្តិសុខ | ឈ្មោះ ឈៀម ឈៀង<br>តួនាទី សន្តិសុខ |